ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិគាំពារសង្គម

លេខ:..........ក.ជ.គ.ស.........

ថ្ងៃសៅរ៍ ១០កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៥

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥

ក្រុមប្រឹក្សាជាតិគាំពារសង្គម បានរៀបចំ **"សប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥"** ក្រោមមូលបទ **"អភិវឌ្ឍប្រព័ន្ធគាំពារសង្គម ដើម្បីការគ្របដណ្តប់កាន់តែប្រសើរ ទៅតាមហានិភ័យនៃវដ្តជីវិត"** រយៈពេល **២ ថ្ងៃពេញ** ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៥ នៅសណ្ឋាគារសេរ៉ីស៊ីដង់សុខា ភ្នំពេញ ដោយមានការចូលរួមពីគណៈអធិបតី ភ្ញៀវកិត្តិយស ជាថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ, អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត, ឯកអគ្គរាជទូត-ឯកអគ្គរដ្ឋទូត, តំណាងដៃគូ-អភិវឌ្ឍន៍ពាក់ព័ន្ធ, មន្ទីរ-អង្គភាពពាក់ព័ន្ធ, និងអ្នកទទួលផល សរុបចំនួនប្រមាណជាង **១ ០០០ នាក់** ទាំងអ្នកចូលរួមដោយផ្ទាល់ និងតាមរយៈប្រព័ន្ធប្រជុំអនឡាញ ព្រមទាំងមានការចូលរួមទស្សនា និងស្តាប់តាមការផ្សាយផ្ទាល់នៅតាមប្រព័ន្ធអនឡាញ និងទំព័រហ្វេសប៊ុកសំខាន់ៗមួយចំនួនផងដែរ។

សូមរម្លឹកជូនថា **សប្តាហ៍គាំពារសង្គម** ជាវេទិកាមួយដែលផ្តល់ឱកាសដល់ភាគីពាក់ព័ន្ធ ដើម្បីពិភាក្សា និង ផ្លាស់ប្តូរទស្សនវិស័យ, គោលនយោបាយ, ចែករំលែកចំណេះដឹង, បទពិសោធ, និង ឧត្តមានុវត្តន៍នៃគោលនយោបាយគាំពារសង្គម ពីប្រទេសផ្សេងៗ, ទាំងក្នុងតំបន់ និង លើសកលលោក, ជាពិសេស ដើម្បីផ្សព្វផ្សាយអំពីវឌ្ឍនភាពនៃប្រព័ន្ធគាំពារសង្គមកម្ពុជា ដល់អ្នកទទួលផល និង សាធារណជន ឱ្យបានជ្រាបកាន់តែច្បាស់ ។

សម្រាប់ ឆ្នាំ២០២៥ នេះ, **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់កិត្តិយសអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធី **«បើកសប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ ២០២៥ និង ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥»** កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ទី២០ ខែកុម្ភៈ ឆ្នាំ២០២៥។

**ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៥-២០៣៥** ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងពិធីនេះ ជាឯកសារគោលនយោបាយដ៏មានសារៈសំខាន់ដែលបានធ្វើការផ្លាស់ប្តូរ ពីអភិក្រមនៃការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម តាមបែបសសរស្តម្ភ ទៅជាការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម និង ការផ្តល់កិច្ចគាំពារ ទៅតាមហានិភ័យនៃវដ្តជីវិត **ទាំង ៧** រួមមានៈ ១). មាតុភាព



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia
nspc.gov.kh / t.me/socialprotectionkh
ទូរសព្ទលេខ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone : (+855) 23 890 666
gs_nspc@mef.gov.kh

និង ហានិភ័យកុមារភាព, ២). ហានិភ័យសុខភាព, ៣). ហានិភ័យការងារ, ៤). ពិការភាព, ៥). និកម្មភាព, ៦). ភាពគ្មានជម្រក, និង ៧). ជរាភាព និង ឧត្តរជីវី។ បន្ថែមលើនេះ, **ក្របខណ្ឌគោលនយោបាយថ្មីនេះ** ក៏បានកំណត់ទិសដៅអន្តរាគមន៍គាំពារសង្គម តាមដំណាក់កាលនីមួយៗ ក៏ដូចជាកំណត់វិធានការគោលនយោបាយ សម្រាប់កិច្ចការឆ្លងវិស័យពាក់ព័ន្ធ ដើម្បីជួយជំរុញដំណើរការនៃការអភិវឌ្ឍ និង ធានាមិនបង្កភាពរាំងស្ទះដល់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម, ទាំងដោយផ្ទាល់ និងដោយប្រយោល។

នៅក្នុងពិធី **«បើកសប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥ និង ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០២៤-២០៣៥», សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍ដ៏ខ្លង់ខ្លស់ថា កម្មវិធីគោលនយោបាយអាទិភាពទាំង **៣** ដែលពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម ក្នុងចំណោមកម្មវិធីគោលនយោបាយអាទិភាពទាំង **៦** ដែលបានដាក់ចេញក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** របស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ពិតជាបាន និងកំពុងជំរុញប្រព័ន្ធគាំពារសង្គម ឱ្យពង្រីកខ្លួនថែមមួយកម្រិតទៀត ដោយក្នុងនោះ បើធៀបនឹងពេលចាប់ផ្តើមដាក់ឱ្យអនុវត្ត **ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ ២០១៦-២០២៥,** វិសាលភាពនៃប្រព័ន្ធគាំពារសង្គមនេះ បានរីកធំជាងមុន **២ ដង** ដោយគ្របដណ្តប់ពលរដ្ឋ ចំនួនជាង **៧,៥ លាននាក់** ត្រឹមដំណាច់ឆ្នាំ២០២៤ នេះ។

កម្មវិធីគោលនយោបាយអាទិភាពទាំង **៣** នេះ រួមមាន៖ ១). ការផ្តល់ការថែទាំសុខភាពឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល; ២). ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស ដែលនេះជាកម្មវិធីជាតិជំនួយសង្គមមួយ; និង ៣). ការធ្វើស្ថាប័នូបនីយកម្មកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ, ក្រុមជនងាយរងគ្រោះក្នុងគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង មានគ្រោះអាសន្ន។ ជាមួយគ្នានេះ, **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងនូវសារដែលចាក់ចំបេះដូងពលរដ្ឋកម្ពុជាគ្រប់រូបថា "**គុណតម្លៃពិតប្រាកដនៃកិច្ចគាំពារសង្គម មិនមែនស្ថិតលើតួលេខមួយមុខប៉ុណ្ណោះទេ តែវាក៏ស្ថិតលើការផ្តល់តម្លៃ និងការទទួលស្គាល់ពីពលរដ្ឋដែលទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម ផងដែរ**"។

បន្ទាប់ពីពិធី "**បើកសប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ២០២៥ និង ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០២៤-២០៣៥**", សប្តាហ៍គាំពារសង្គមកម្ពុជា ឆ្នាំ ២០២៥ បានបន្តប្រព្រឹត្តទៅតាមរបៀបវារៈ ដូចការគ្រោងទុក ដោយមានបទបង្ហាញគន្លឹះ និង កិច្ចពិភាក្សាជាបន្តបន្ទាប់ ដែលបែងចែកជា **៥ វគ្គ** គឺ៖ ១) **ការបន្តអភិវឌ្ឍប្រព័ន្ធគាំពារសង្គម**, ២) **វឌ្ឍនភាពនៃប្រព័ន្ធគាំពារសង្គមនៅកម្ពុជា**, ៣) **ការពង្រឹងប្រព័ន្ធគាំពារសង្គមនៅកម្ពុជា**, ៤) **ឆ្ពោះទៅការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ សម្រាប់កិច្ចគាំពារសង្គម**, និង ៥) **ការតស៊ូមតិរបស់យុវជនលើប្រធានបទពាក់ព័ន្ធនឹងប្រព័ន្ធគាំពារសង្គម**។

លទ្ធផល និងបទពិសោធ ដែលទទួលបានតាមរយៈបទបង្ហាញ កិច្ចពិភាក្សា ក៏ដូចជាការតស៊ូមតិក្នុងវគ្គនីមួយៗ នឹងក្លាយជាធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំគោលនយោបាយគាំពារសង្គម ក៏ដូចជាបន្តកសាង និងពង្រឹងប្រព័ន្ធគាំពារសង្គមកម្ពុជា ឱ្យកាន់តែមានភាពធន់ ប្រកបដោយភាពទន់ភ្លន់ និងចីរភាព។

ជារួម, **សប្តាហ៍គាំពារសង្គមកម្ពុជា ២០២៥** បានប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា ជាមួយនឹងការទទួលបានធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំគោលនយោបាយគាំពារសង្គម ក៏ដូចជាបន្តកសាង និងពង្រឹងប្រព័ន្ធគាំពារសង្គមកម្ពុជា ឱ្យកាន់តែមានភាពធន់ប្រកបដោយភាពទន់ភ្លន់ និងចីរភាព ជាពិសេសក្រសួងស្ថាប័នក្រោមឆ័ត្រក្រុមប្រឹក្សាជាតិគាំពារសង្គមបានទទួលអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ពាក់ព័ន្ធនឹងការរួមគ្នាផ្តល់កិច្ចគាំពារសង្គម និងសេវាពាក់ព័ន្ធ ជូនពលរដ្ឋគោលដៅ ឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ស្របតាមស្មារតី "**មិនបោះបង់ពលរដ្ឋណាម្នាក់**" ។

ស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងការផ្សព្វផ្សាយអំពីប្រព័ន្ធគាំពារសង្គមកម្ពុជា ឱ្យបានកាន់តែទូលំទូលាយ រហូតអាចដល់កម្រិតតំបន់, ក្រុមប្រឹក្សាជាតិគាំពារសង្គមនឹងរៀបចំពិធីនេះ នៅឆ្នាំបន្តបន្ទាប់ទៀត ដោយមានកិច្ចសហការខ្ពស់ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកម្មវិធីគោលនយោបាយអាទិភាព របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាសំដៅរួមចំណែកក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយកម្ពុជាទៅប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម**

NATIONAL SOCIAL PROTECTION COUNCIL
SOCIAL PROTECTION CAMBODIA